សេចក្តីប្រកាសព័ត៌មាន

ស្តីពី

សន្និសីទជាន់ខ្ពស់ (High-Level Conference)

ទន្ទឹមគ្នានឹងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន និង កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន

ក្រោមប្រធានបទ: "ហិរញ្ញប្បទានប្រកបដោយចីរភាព÷ ការកៀរគរហិរញ្ញប្បទានសម្រាប់ការស្តារសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩"

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២២

កាលពីព្រឹក ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២២, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំ សន្និសីទជាន់ខ្ពស់ស្តីពី **"ហិរញ្ញប្បទានប្រកបដោយចីរភាព÷ ការកៀរគរហិរញ្ញប្បទានសម្រាប់ការស្តារសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩"** , ទន្ទឹមគ្នានឹងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី **២៦** (AFMM) និង កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី ៨ (AFMGM), ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ឆ្នាំ ២០២២ ។ សន្និសីទជាន់ខ្ពស់នេះគឺជាវេទិកាមួយដ៏មានសារៈសំខាន់សម្រាប់ឆ្ពោះទៅ **វេទិកាពិភាក្សាជាសកលអាស៊ានលើកទី២** ដែលគ្រោងនឹងរៀបចំជាបន្ទាប់ក្នុងអំឡុង **កិច្ចប្រជុំកំពូលអាស៊ាន**នៅចុងឆ្នាំ២០២២ ខាងមុខនេះ ។ សន្និសីទនេះមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំនៃក្រសួងហិរញ្ញវត្ថុ និង ធនាគារកណ្តាលអាស៊ាន , តំណាងជាន់ខ្ពស់ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន និងគ្រឹះស្ថានស្រាវជ្រាវជាច្រើន ជាពិសេស ការចូលរួមពីសំណាក់ **ឯកឧត្តម និង លោកជំទាវ ជា រដ្ឋមន្ត្រីហិរញ្ញវត្ថុនៃប្រទេសប្រ៊ុយណេ, ឥណ្ឌូនេស៊ី, ភូមា, សិង្ហបុរី, ថៃ និងវៀតណាម និង ទេសាភិបាលធនាគារកណ្តាលនៃប្រទេសឥណ្ឌូនេស៊ី, ភូមា និង ហ្វីលីពីន ព្រមទាំង ឯកឧត្តមអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាស៊ាន** ។

ជារួម វេទិកានេះបានផ្តល់ធាតុចូលដ៏មានតម្លៃជាច្រើនសម្រាប់អ្នករៀបចំគោលនយោបាយ ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ សម្រាប់គិតគូរ ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ទាក់ទងនឹងវិបត្តិជំងឺកូវីដ-១៩ ជាពិសេស ផលប៉ះពាល់ដែលនៅសេសសល់ (scarring effects)ព្រមទាំងហានិភ័យ និងបញ្ហាប្រឈមថ្មីៗ បណ្តាល

មកពីជម្លោះដែលកំពុងកើតមាននៅក្នុងតំបន់អឺរ៉ុបខាងកើត។ ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជានាពេលបច្ចុប្បន្ន, សន្និសីទនេះ បានគូសបញ្ជាក់អំពីតួនាទីដ៏សំខាន់នៃគោលនយោបាយសារពើពន្ធ និងការអភិវឌ្ឍបៃតងក្នុងការធានាឱ្យបាននូវការស្តារសង្គមសេដ្ឋកិច្ចក្នុងតំបន់ឡើងវិញប្រកបដោយចីរភាព និងបរិយាប័ន្ន ។ **ជាពិសេស ស្របពេលបណ្តាលប្រទេសជាច្រើនក្នុងតំបន់ប្រឈមនឹងការកើនឡើងតម្រូវការចំណាយ, ការពង្រឹងអភិបាលកិច្ចចំណាយសាធារណៈជាគន្លឹះនៃការគ្រប់គ្រងឱ្យបានល្អប្រសើរនូវស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល ខណៈដែលការបង្កើនចំណូលបន្ថែម តាមរយៈការពង្រឹងគុណភាពគោលនយោបាយពន្ធ, ការពង្រីកមូលដ្ឋានយកពន្ធ និងការពង្រឹងប្រសិទ្ធភាពនៃរដ្ឋបាលពន្ធ គឺជាកិច្ចការអាទិភាពចាំបាច់បំផុត ដើម្បីធានាចីរភាពសារពើពន្ធ ។**

ជាផ្នែកសំខាន់មួយនៃកម្មវិធីនេះ, កិច្ចពិភាក្សា (panel discussion) ដែលមានការចូលរួមដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុឥណ្ឌូនេស៊ី, រដ្ឋមន្ត្រីហិរញ្ញវត្ថុសិង្ហបុរី, ប្រធានសេដ្ឋវិទូ នៃធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) និងប្រធានប្រចាំតំបន់នៃធនាគារពិភពលោក (World Bank) និង សម្របសម្រួលដោយអនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបំផុសឱ្យមានការពិភាក្សាផ្លាស់ប្តូរយោបល់ប្រកបដោយស្មារតីស្ថាបនា និងផ្តល់អនុសាសន៍ប្រាកដនិយមជាច្រើន ដើម្បីដោះស្រាយបញ្ហានានា ពាក់ព័ន្ធនឹងគោលនយាបាយសារពើពន្ធ, ការផ្តល់ហិរញ្ញប្បទាន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនបៃតង ។

ក្នុងនោះ លោកជំទាវរដ្ឋមន្ត្រីហិរញ្ញវត្ថុនៃប្រទេសឥណ្ឌូនេស៊ីបានចែករំលែកនូវបទពិសោធន៍សំខាន់ៗ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសរៀងៗខ្លួន ក្នុងគោលដៅធានានិរន្តរភាពនៃការស្តារសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ជាពិសេស តាមរយៈការអនុវត្តគោលនយោបាយប្រកបដោយភាពបត់បែនខ្ពស់ ក្នុង (១).ការដោះស្រាយនូវបញ្ហាចំពោះមុខនានា ដូចជា ការកើនឡើង នូវតម្រូវការចំណាយ, ការធ្លាក់ចុះចំណូលរដ្ឋ, និង (២). ការធានាបាននិរន្តរភាព និងចីរភាពនៃការជំរុញការស្តារឡើងវិញនូវកំណើនសេដ្ឋកិច្ច ។ ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រីហិរញ្ញវត្ថុប្រទេសសិង្ហបុរី ក៏បានផ្តោតលើសារៈសំខាន់នៃការប្រមូលចំណូលពន្ធ ប្រកបដោយភាពសមធម៌ និងមានចរិតកើនឡើងស្របតាមកំប្រាក់ចំណូល ឬមូលដ្ឋានយកពន្ធជាក់ស្តែង (Fair and Progressive tax collection), និង ការអនុវត្តវិធានការសារពើពន្ធក្នុងការដោះស្រាយនូវផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ ។ល។ ទន្ទឹមនេះ ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងធនាគារពិភពលោក បានសង្កត់ធ្ងន់លើការបង្កើនហិរញ្ញប្បទានប្រកបដោយចីរភាព និង ការអភិវឌ្ឍបៃតង ដើម្បីជំរុញនិរន្តរភាព និងបរិយាប័ន្ន នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចអាស៊ាន ។ តួយ៉ាង ដើម្បីបំពេញនូវកង្វះខាតការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបៃតង, បណ្តាប្រទេសជាសមាជិកអាស៊ានត្រូវបានជំរុញឱ្យអាចប្រើប្រាស់ឧបករណ៍ហិរញ្ញប្បទានបៃតង (Green Catalytic

Financing Facility) ដើម្បីទទួលបានហិរញ្ញប្បទានសម្រាប់ការជំរុញចីរភាពបរិស្ថាន ដែលនឹងរួមចំណែកសម្រេចបាននូវគោលដៅនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគាំទ្រការស្តារបៃតងនៃប្រទេសសមាជិកអាស៊ាន ។

ក្នុងសុន្ទរកថាបិទសន្និសីទជាន់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានចូលរួមចែករំលែកនូវបទពិសោធន៍របស់កម្ពុជា លើការអនុវត្តគោលនយោបាយសារពើពន្ធក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងរយៈពេល ២ ឆ្នាំកន្លងមកនេះ, ជាពិសេស ការកែទម្រង់សារពើពន្ធ ដែលបាននិងកំពុងអនុវត្តព្រមទាំងកត់សម្គាល់ថា **កម្ពុជាបាន ផ្តល់អាទិភាពខ្ពស់ក្នុងការពង្រឹងប្រសិទ្ធភាពចរិកា ទាំងកម្រិតវិភាជ និងប្រតិបត្តិការ, ការកែលម្អរដ្ឋបាលពន្ធ និងធ្វើវិចារណកម្មគោលនយោបាយពន្ធ ក៏ដូចជាការពង្រឹងការធ្វើពិពិធកម្មមូលដ្ឋាននៃការប្រមូលចំណូលដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ម្យ៉ាង, និងម្យ៉ាងទៀត ដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យត្រលប់ទៅគន្លងនូវកំណើនសក្តានុពល** ។ បន្ថែមលើនេះ កម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព ដើម្បីពង្រឹងភាពធន់នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។ <u>ជារួម ក្នុងក្របខណ្ឌតំបន់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានផ្តោតសំខាន់លើការស្វែងរកដំណោះស្រាយប្រកបដោយភាពប្រាកដនិយម និងការគិតគូរគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមផ្នែកសារពើពន្ធ និងស្វែងរកគំនិតផ្តួចផ្តើមហិរញ្ញប្បទានបៃតង ដើម្បីស្តារសេដ្ឋកិច្ចក្នុងតំបន់ឡើងវិញប្រកបដោយបរិយាប័ន្ន និងចីរភាព, ដោយផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការកាន់តែស្អិតរមួតរវាងប្រទេសសមាជិក និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ នីមួយៗ។</u>

ជាកិច្ចបញ្ចប់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ប្រធានអង្គប្រជុំបានសំដែងនូវការថ្លែងអំណរគុណជាពិសេសចំពោះរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុឥណ្ឌូនេស៊ី លោកជំទាវ Sri Mulyani Indrawati, រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុសិង្ហបុរី ឯកឧត្តម Lawrence Wong, និង តំណាងជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងធនាគារពិភពលោក ដែលបានចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សា (panel discussion)។ ទន្ទឹមនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានវាយតម្លៃខ្ពស់ចំពោះតំណាងប្រទេសសមាជិកអាស៊ាននីមួយៗ, អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាស៊ាន និងតំណាងមកពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ, ដៃគូអភិវឌ្ឍន៍, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, វិស័យឯកជន និងគ្រឹះស្ថានអប់រំ ដែលបានចូលរួមក្នុងសន្និសីទនេះ ប្រកបដោយការយកចិត្តទុកដាក់។